# ដំណាំស្ពៃចង្កឹះ

## ១. ការរៀបចំដី

### ក-ការរៀបចំថ្នាលសាបកូន

- រដូវប្រាំងៈ ត្រូវភ្ជួរ ឬកាប់ដីឱ្យជ្រៅ ហាលដីឱ្យស្ងួត រយៈពេល ៣-៧ ថ្ងៃ ក្រោយពីដីស្ងួតហើយត្រូវវាយ ឬ រាស់បំបែកដីឱ្យម៉ត់ លើកជាថ្នាលដែលមានទទឹងពី ៦០-៨០ ស.ម កំពស់ ១០-១៥ ស.ម បណ្តោយ ទៅតាមជាក់ស្តែងរបស់ដី ចន្លោះថ្នាលពី ៣០-៤០ ស.ម កៀរពង្រាបដីឱ្យស្មើល្អ ធានារក្សាសំណើមបានយូរ ធ្វើឱ្យកូនស្ពៃលូតលាស់ស្មើគ្នាល្អ ។

-នៅរដូវវស្សាៈ មិនខុសពីរដូវប្រាំងឡើយតែយើងត្រូវរកទីកន្លែងទួលខ្ពស់មិនជាំទឹក និងត្រូវមានគំរបការពារភ្លៀងសំរាប់គ្របដីឱ្យស្ងួតចន្លោះពី ៧ ថ្ងៃ បន្ទាប់មកលើកជារងឱ្យបានកំពស់ពី ១៥-២០ ស.ម ទទឹងពី ៨០-១០០ ស.ម ។ ថ្នាលសាបកូនត្រូវកៀរដីឱ្យបានស្មើមានប្រឡាយបញ្ចេញទឹក ។

### ខ-ការរៀបចំដីសំរាប់ស្ទូង

-នៅរដូវវស្សា ការរៀបចំថ្នាលសំរាប់ស្ទូង គឺត្រូវភ្ជួរដីឱ្យបានជំរៅពី ១៥-២០ ស.ម ហើយហាលដីឱ្យស្ងួតរយៈពេលពី ៥-៧ ថ្ងៃ ទើបរាស់បំបែកដី ប្រមូលយកស្មៅចេញ បន្ទាប់មកហាលដីឱ្យបាន ២-៣ ថ្ងៃ ។ ក្រោយមកទៀតភ្ជួរប្រែដី ហាលឱ្យបានរយៈពេល ៣-៥ ថ្ងៃ ទើបរាស់ និងកៀរដីឱ្យស្មើល្អ ។

-របៀបលើករង ក្បាលរងត្រូវធ្វើឱ្យត្រឹមគ្នាដែលមានទទឹងពី ៨០-១០០ ស.ម បណ្តោយជាការល្អត្រូវមានប្រវែង ១០-២០ ម៉ែត្រ កំពស់រងពី ១៥-២០ ស.ម ។

ចំពោះនៅរដូវប្រាំងការរៀបចំដីដូចគ្នា គេនិយមដាំនៅលើដីស្រែហើយលើករងទាបជាង ដើម្បីកាត់បន្ថយការប្រើប្រាស់ទឹក។

## ២. បច្ចេកទេសដាំដុះ

ដំណាំស្ពៃចង្កឹះគេអាចដាំបាន ២ វិធីគឺ ការសាបកូនហើយដកទៅស្ទូង និងការព្រួសដោយគ្រាប់ផ្ទាល់ក៏បាន ។

### ក-របៀបសាបគ្រាប់ពូជ

មុនពេលសាបគ្រាប់ពូជត្រូវយកជីកំប៉ុស្ត ឬជីលាមកសត្វចំនួន ២ បង្គី ឬ ៣០ គ.ក្រ ទៅបាចលើថ្នាល ដែលមានផ្ទៃដី ១០-១៥ ម២ រួចហើយយកជី ១៥.១៥.១៥ ចំនួន ២០០ ក្រាម ឬ ប្រាំស្លាបព្រាបាយ និង ថ្នាំ Furadan $3^H$ ចំនួន ៥០ ក្រាម ទៅបាចលើថ្នាល ហើយរាស់លប់ទៅក្នុងដី ក្រោយមកស្រោចទឹកឱ្យជោគ ។ គ្រាប់ពូជត្រូវយកមកត្រាំជាមួយទឹកដែលបានលាយជាមួយថ្នាំ Captan ៥ ក្រាម លាយជាមួយទឹក ១ លីត្រ ត្រាំរយៈពេល ១០ នាទីបន្ទាប់មកស្រង់ហាលគ្រាប់ ឱ្យស្រស់ទឹកទើបយកទៅសាប ។ ត្រូវប្រើគ្រាប់ពូជ ចំនួន ១៥-១៦ ក្រាម ឬ ១ ស្លាបព្រាបាយ ក្នុងផ្ទៃដី ១០ ម$^២$ ។

ក្រោយសាបរួចហើយ ព្រោចកំណាត់ចំបើងស្ងួតខ្លីៗ ឱ្យពេញលើថ្នាលហើយស្រោចទឹកឱ្យជោគទើបគ្របស្លឹកចេកពីលើ បន្ទាប់មកស្រោចទឹករាល់ថ្ងៃ គឺមួយថ្ងៃ ២ លើក ព្រឹក និងល្ងាច ។ រយៈពេលក្រោយសាបចំនួន ២ យប់ត្រូវបកស្លឹកចេកនោះចេញពេលនោះកូនស្ពៃចាប់ផ្តើមដុះ ។

**ខ-របៀបស្ទូង**

ក្រោយសាបរយៈពេល ១៤-១៦ថ្ងៃ កូនស្ពៃមានសន្លឹក ៣កំពស់ពី ៨-១០ ស.ម គេអាចដកកូនស្ពៃទៅស្ទូងបាន។ មុនពេលដកកូនស្ពៃត្រូវស្រោចទឹកឱ្យជោករយៈពេល ២០-៣០ នាទី។ ចំពោះថ្នាលសំរាប់ស្ទូង ដំបូងត្រូវយកជីធម្មជាតិពុកផុយល្អចំនួន ២ បង្គី ស្មើនឹង ៣០ គ.ក្រ ជី ១៥.១៥.១៥ ចំនួន ២០០ ក្រាមស្មើ នឹង ២ខាំ ទៅបាចលើរងប្រវែង ១០ -១៥ ម ហើយរាស់លប់ទៅក្នុងដី បន្ទាប់មកស្រោចទឹកឱ្យជោគទើបស្ទូងតាមក្រោយ។ ត្រូវស្ទូងពេលថ្ងៃរសៀលត្រជាក់ ចន្លោះគុម្ព និងចន្លោះជួរដែលត្រូវស្ទូងគឺ ២៥ x ២០ ស.ម ក្រោយស្ទូងហើយត្រូវស្រោចទឹកឱ្យជោគ ។ ដើម្បីបន្ថយកំដៅដី និងការពារការហាបដីព្រមទាំងអាចរក្សាសំណើមដីបានយូរចាំបាច់ត្រូវព្រាចកំណាត់ចំបើងស្ងួតឱ្យសព្វល្អពេញលើផ្ទៃរង ហើយស្រោចទឹក ៣ ដង ក្នុង១ថ្ងៃ ស្រោចក្នុងរយៈពេល ៣ ថ្ងៃ ក្រោយស្ទូង ។

**គ-របៀបដាំដោយសាបគ្រាប់ផ្ទាល់**

ក្រោយពីការរៀបចំរងហើយ ត្រូវយកជីកំប៉ុស្ត និង ជី ១៥.១៥.១៥ ចំនួនដូចខាងលើមកព្រាចលើថ្នាល ហើយរោយថ្នាំ Furadan 3H ចំនួន ៣ ស្លាបព្រាបាយ ហើយរាស់លប់ទៅក្នុងដី បន្ទាប់មកស្រោចទឹកឱ្យជោគ។ ចំពោះគ្រាប់ពូជដែលត្រូវយកមកព្រួសត្រូវព្រួសឱ្យរង្វើល១ ក្នុងកំរិតកន្លះស្លាបព្រាបាយស្មើនឹង ៨ ក្រាម លើផ្ទៃថ្នាល ១០ ម២ ។



ក្រោយពីព្រួសហើយត្រូវព្រាចកំណាត់ចំបើងស្ងួតពីលើទើបស្រោចទឹកតាមក្រោយ ។ ដើម្បីឱ្យកូនស្ពៃដុះស្មើគ្នាល្អ រយៈពេល ២-៣ថ្ងៃ ដំបូងត្រូវស្រោចទឹក ៣ដង ក្នុង១ថ្ងៃ។ ក្រោយពេលកូនស្ពៃដុះបានរយៈពេល ៧-១០ ថ្ងៃ គេត្រូវដករំលោះកូនស្ពៃចេញខ្លះនៅត្រង់កន្លែងដែលញឹកពេក គឺត្រូវរក្សាទុកចំនួនដើមស្ពៃត្រឹមតែ ២០-២២ ដើម/ម២ ។

## ៣. ការថែទាំ

**ក-ការស្រោចទឹក**

ការស្រោចទឹកអាចធ្វើបានច្រើនរបៀបគឺ ស្រោចដោយប៉ោតមួយថ្ងៃ ២លើក ព្រឹក និងល្ងាច។ ដំណាំស្ពៃចង្កឹះមិនត្រូវការទឹកច្រើនពេកទេ តែវាត្រូវការជាប្រចាំរៀងរាល់ថ្ងៃ ។ កសិករខ្លះអាចស្រោចស្រពដោយម៉ាស៊ីន គឺដាក់ជិពួយផ្កាឈូកបាញ់ឱ្យជោគ ១ថ្ងៃម្តង តែវិធីនេះធ្វើឱ្យដីឆាប់ហាប់ចាំបាច់ត្រូវគ្របចំបើងឱ្យក្រាស់ ។

**ខ-ការដាក់ជី**

ស្ពៃចង្កឹះជាបន្លែដែលត្រូវការជាចាំបាច់នូវជីជាតិ អាសូត ផូស្វាត និងប៉ូតាស្យូម ប៉ុន្តែសេចក្តីត្រូវការនេះត្រូវបែងចែកទៅតាមដំណាក់កាលលូតលាស់របស់វា ។ ប្រភេទបន្លែស្លឹកត្រូវការជាតិអាសូតច្រើនជាងគេ ដូច្នេះការដាក់ជីត្រូវអនុវត្តតាមប្រភេទដី អាយុកាល និងប្រភេទជី ។ ក្រោយសាបបាន ពី ១០-១២ ថ្ងៃ ត្រូវយកជីអ៊ុយរ៉េ ១ ស្លាបព្រាបាយលាយទឹក

២០ លីត្រ ស្រោចលើផ្ទៃរង ១០-១៥ ម² ហើយត្រូវស្រោចទឹកលាងតាមក្រោយឱ្យជោគនៅពេលកូនស្ពៃមានអាយុពី ១០-២០ ថ្ងៃ ត្រូវយកជី ១៥.១៥.១៥ ចំនួន ២ខាំកន្លះបាចលើផ្ទៃថ្នាល ១០-១៥ ម² បើប្រើលើផ្ទៃដី ១ ហិកតា ត្រូវប្រើក្នុងកំរិត ១៥០-២០០ គ.ក្រ ដោយរោយតាមចន្លោះគុម្ពហើយស្រោចទឹកឱ្យជោគភ្លាម ។ បន្ទាប់មកទៀតរយៈពេលមួយអាទិត្យម្តង ប្រើជីអ៊ុយរ៉េតាមកំរិតដូចពីមុន ។ ចំពោះការដាំដោយស្ទូងក្រោយពីស្ទូងកូនរយៈពេលពី ៧-១០ ថ្ងៃ យើងយកជីអ៊ុយរ៉េចំនួន ១ ស្លាបព្រាបាយលាយទឹក ២០ លីត្រ ស្រោចលើផ្ទៃដី ១០-១៥ ម២ រយៈពេល ១ អាទិត្យម្តង ។

**គ-ការសំអាតស្មៅរ្ងំដីពូនគល់**

ត្រូវដកស្មៅចេញនិងជ្រំជ្រួយដីឱ្យធូរដោយប្រើកូនចបតូចៗ រយៈពេលពី ៧-១០ ថ្ងៃ ក្រោយសាប ឬ ស្ទូងដើម្បីរក្សាសំណើមបានល្អ ។ មួយអាយុកាលរបស់ស្ពៃអ្នកអាចដកស្មៅចំនួន ២-៣ លើក ។ ចំពោះការជ្រំជ្រួយដីធ្វើឡើងតែមួយលើកតែប៉ុណ្ណោះ ។

## ៤. ការគ្រប់គ្រងសត្វល្អិត និងជំងឺ

សត្វល្អិតបំផ្លាញដែលធ្លាប់ជួបប្រទះមានៈ ដង្កូវស៊ីញ៉ៅ ដង្កូវខៀវ ដង្កូវខៀវ ដង្កូវស៊ីស្លឹក និងកាត់ស្លឹក ដើម ទាគូ ដង្កូវហ្វូង ដង្កូវយោលទោង និងចៃ។ ជំងឺដែលធ្លាប់ជួបប្រទះមានៈ ជំងឺផ្សិតរលួយគល់ ជំងឺស្រពោន ដើមស្រស់ពុកឫស ជំងឺបាក់តេរីរលួយទន់ ជំងឺបាក់តេរីអុចលើស្លឹក ។(ការគ្រប់គ្រង និងកំចាត់ដូចក្នុងឯកសារដំណាំខាត់ណា)។

## ៦. ការប្រមូលផល

គេអាចប្រមូលផលដំណាំស្ពៃបន្ទាប់ពីណាំបានរយៈពេលពី ២០-២៥ថ្ងៃ ។ មុនពេលប្រមូលផលរយៈពេល ១៤ថ្ងៃ ត្រូវបញ្ឈប់ការប្រើថ្នាំពុលផ្សេងៗ និងរយៈពេលពី ២-៣ថ្ងៃ ផ្អាកការស្រោចទឹក។ ការប្រមូលផលនៅពេលព្រឹកត្រជាក់ចាប់ពីម៉ោង ៨ ទៅម៉ោង ១០។ របៀបប្រមូលផលគេប្រើកូនកាំបិតមកកាត់ក្បែរគល់ផុតពីដី រួចកាត់ស្លឹកចាស់ៗចោល ២-៣ ធាង



រួចយកទៅដាក់តំរៀបក្នុងឡាំង ឬ កញ្ជើរធំមានខ្យល់ចេញចូលដាក់ក្រោមម្លប់ក្រដាក់ក្រោមដើមឈើ បន្ទាប់មកត្រូវដឹកជញ្ជូនចេញភ្លាមកុំអោយត្រូវថ្ងៃក្តៅ។ ជាទូទៅទិន្នផលជាមធ្យមរបស់វាផ្តល់ពី ១៨-២២ តោន/ហត ។